ភ្នំពេញ , ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៣

# សារាចរ លេខ ០៤ សរ

## រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

## សូមគោរពជូនលិខិតជូន

ព្រះអង្គស្តេចក្រុមហ្លួង និង ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ព្រះអង្គស្តេចក្រុមហ្លួង និង ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខជាតិ

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

អស់លោក អភិបាល ខេត្ត ក្រុង ទូទាំងប្រទេស

**កម្មវត្ថុ :** អំពីវិធានការ ពង្រឹងកិច្ចការពារទ្រព្យសម្បត្តិរបស់អាជ្ញាធរ អ៊ុនតាក់ ។

**យោង :** សារាចរលេខ ០២ សរ ស្តីពីរបៀបរៀបរយ និង សន្តិសុខ សាធារណៈ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

នៅពេលដែលអាណត្តិរបស់អាជ្ញាធរ អ៊ុនតាក់ នឹងត្រូវបញ្ចប់នាពេលឆាប់ៗ ខាងមុខ រដ្ឋាភិបាលជាតិបណ្តោះអាសន្នបានសង្កេតឃើញមានបាតុភាព លួច ប្លន់ទ្រព្យសម្បត្តិរបស់អាជ្ញាធរ អ៊ុនតាក់ ពិសេសគឺ រថយន្ត និងសម្ភារៈសំរាប់តំលើងសំណង់អាគារ បានកើតឡើងក្នុងកំរិតមួយគួរអោយព្រួយបារម្ភ នាប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ។

អំពើអសកម្មខាងលើនេះ បើសិនជាមានការជាប់ទាក់ទិនជាមួយនិងមន្ត្រីរដ្ឋបាលនៅ និង កន្លែង ឬ កងកំលាំងប្រដាប់អាវុធមួយចំនួនណានោះរបស់យើងដូចចែងក្នុងលិខិតរបស់អ៊ុនតាក់ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣ នោះគឺជាសកម្មភាពល្មើសច្បាប់ ។

ចំពោះមុខសភាពការណ៍នេះ ទោះបីក្នុងករណីណាក៏ដោយរដ្ឋាភិបាលជាតិបណ្តោះអាសន្ន កម្ពុជា ចេញបញ្ជាអោយក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ក្រសួងហិរញ្ញវត្ថុ ( គយនិងរដ្ឋាករ ) ក្រសួងដឹកជញ្ជូនសហការជាមួយអាជ្ញាធរអ៊ុនតាក់ និង ខេត្ត ក្រុង ចាត់គ្រប់វិធានការជាបន្ទាន់ ដូចតទៅ ÷

ក/ ធ្វើអន្តរាគមបង្ក្រាបបានទាន់ពេល ក្នុងករណីកើតមានអំពើលួចប្លន់នេះ ។

ខ/ ស្រាវជ្រាវតាមដានរកអោយឃើញជនល្មើស និងជនរួមគំនិតឃុបឃិតក្នុងអំពើលួចប្លន់ទ្រព្យសម្បត្តិរបស់អាជ្ញាធរអ៊ុនតាក់ ។

គ/ ចងក្រងសំណុំរឿងហើយបញ្ជូនជនល្មើស ព្រមទាំងវត្ថុតាងទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

ឃ/ ពង្រឹងការពិនិត្យការចេញចូលតាមច្រកព្រំដែន និង ផែនៅតាមព្រំដែនអោយបានម៉ឺងម៉ាត់ ។

៦/ អង្គភាពមានសមត្ថកិច្ច ក្នុងការផ្តល់លេខយានយន្តត្រូវពិនិត្យប្រភព និងលិខិតស្នាមអោយបានច្បាស់លាស់ ។

រដ្ឋាភិបាលជាតិបណ្តោះអាសន្ន កម្ពុជា និង ខិតខំធ្វើសហប្រតិបត្តិការអោយកាន់តែជិតស្និទ ថែមទៀត ជាមួយអាជ្ញាធរអ៊ុនតាក់ ត្រូវថ្នាក់ដើម្បីគ្លាច់បានពត៌មាន ទាន់ពេលវេលា ងាយស្រួលក្នុងការ ធ្វើប្រតិបត្តិការស្រាវជ្រាវតាមដានត្រួតពិនិត្យ អំពើលួចឆ្លូន់ទ្រព្យសម្បត្តិរបស់អាជ្ញាធរអ៊ុនតាក់ ។

ទទួលបានសារាចរនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ក្រសួង ហិរញ្ញវត្ថុ ( គយនិង រដ្ឋាគរ ) ក្រសួងដឹកជញ្ជូន និង ខេត្ត ក្រុង ត្រូវចាត់តាំងអនុវត្តដោយរួមសហការជា មួយអាជ្ញាធរអ៊ុនតាក់ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្ថលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

****

ភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

## សារាចរ លេខ ០៥ សរ

## សូមទូលថ្វាយ និង ជំរាបជូន

- ព្រះអង្គម្ចាស់ ឯកឧត្តមរដ្ឋមន្ត្រីគ្រប់ក្រសួង
- អស់លោក អភិបាលគ្រប់ខេត្តក្រុង

**កម្មវត្ថុ** : អំពីបញ្ហាមួយចំនួនដំរិញការតែងតាំងមន្ត្រី និយោជិត សំរាប់ក្រសួង ស្ថាប័ននីមួយៗ ។

**យោង** : សេចក្តីប្រកាស នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ចុះថ្ងៃទី ០២ខែ កក្កដា ឆ្នាំ១៩៩៣ ។

បច្ចុប្បន្ននេះ នៅតាមក្រសួងស្ថាប័នមួយចំនួន ក្នុងនោះមានក្រសួងដែលមានពីមុនមកស្រាប់ និង ក្រសួងដែលទើបនឹងបង្កើតថ្មីផង មានលេចចេញនូវបាតុភាពជ្រើសរើសគ្រប់ខ័ណ្ឌ និង បុគ្គលិកថ្មីបំរុង និង តែងតាំង បន្ថែមនៅក្នុងក្រសួង និង ស្ថាប័នទាំងនេះទៀត នៅពេលដែលក្រសួង និង ស្ថាប័ននីមួយ ៗ កំពុងត្រូវរែកអំរែកយ៉ាង ធ្ងន់ធ្ងរ ដោយសារមានចំនួនមន្ត្រី បុគ្គលិក និយោជិត ច្រើនលើសចំនួនដែល ចាំបាច់រួចទៅហើយ និង